**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

លេខៈ ១៤១០ អយក.ហវ

ថ្ងៃអង្គារ ៨រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣

**ជម្រាបមក**

**-ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានអង្គភាពក្រោមឱវាទក្រសួង**

**-លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

**កម្មវត្ថុ ៖** សំណើអញ្ជើញសមាសភាពចូលរួមវគ្គសិក្ខាសាលាពិគ្រោះយោបល់ ស្ដីពី **"នីតិវិធីហិរញ្ញវត្ថុនិងការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ (SOF) ជាលក្ខណៈ Web Application"** ក្នុងឆ្នាំ២០២៣។

**យោង ៖** ផែនការសកម្មភាពរបស់នាយកដ្ឋានហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៣។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ លោក លោកស្រីប្រធាន** ជ្រាបថា៖ ក្រសួងអប់រំ យុវជន និងកីឡា បានកំពុងអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ (SOF) ដែលមានលក្ខណៈអនឡាញដោយបានបន្ថែមមុខងារប្រតិបត្តិការថ្មីៗដើម្បីបង្កភាពងាយស្រួលនិងស្វ័យប្រវត្តិកម្មដូចជា៖ ការគ្រោងថវិកាSOFប្រចាំឆ្នាំ ការអនុវត្តថវិកាប្រចាំឆ្នាំ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ កិច្ចបញ្ជិការសម្ភារ និងគ្រប់គ្រងបុគ្គលិក។ល។ ក្នុងន័យនេះ ក្រសួងនឹងរៀបចំវគ្គសិក្ខាសាលាពិគ្រោះយោបល់ ស្ដីពី "នីតិវិធីហិរញ្ញវត្ថុនិងការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា សម្រាប់ការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ (SOF) ជាលក្ខណៈ Web Application" ដើម្បីប្រមូលធាតុចូលបន្ថែមពីសំណាក់មន្ត្រីជំនាញនៃអង្គភាពពាក់ព័ន្ធដែលមានបទពិសោធន៍ ធ្វើយ៉ាងណាឱ្យប្រព័ន្ធមានសង្គតិភាពទៅនឹងនីតិវិធីនិងការងារជាក់ស្តែង ដែលស្របតាមចក្ខុវិស័យនៃកំណែទម្រង់វិស័យអប់រំបច្ចុប្បន្ន ដោយផ្តោតសំខាន់លើការអភិវឌ្ឍធនធានមនុស្សប្រកបដោយចីរភាព ព្រមទាំងការអប់រំបែបឌីជីថល (Digital Education)។ ដូចនេះ ក្រសួងអប់រំ យុវជន និងកីឡា ចាំបាច់ត្រូវរៀបចំវគ្គសិក្ខាសាលាឱ្យស្របតាមផែនការសកម្មភាព ដែលបានគ្រោងទុក។

**បញ្ជាក់៖**

-សូមភ្ជាប់មកជាមួយនូវកុំព្យូទ័រយួរដៃ (Laptop) សម្រាប់ការអនុវត្តផ្ទាល់ជាមួយក្រុមការងារ

-វគ្គសិក្ខាសាលានេះប្រើប្រាស់ថវិកាគម្រោងមូលនិធិភាពជាដៃគូដើម្បីអភិវឌ្ឍន៍សមត្ថភាព (CDPF)។

អាស្រ័យហេតុនេះសូម **ឯកឧត្តម លោកជំទាវ លោក លោកស្រីប្រធាន** ចាត់តាំងសមាសភាពចូលរួមតាមកាលបរិច្ឆេទនិងទីកន្លែង ដូចមានក្នុងតារាងជូនភ្ជាប់ឱ្យបានទាន់ពេលវេលា។

សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រីប្រធាន** ទទួលនូវគារវកិច្ចអានដ៏ស្មោះពីខ្ញុំ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**

-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"

-កាលប្បវត្តិ

-ឯកសារនាយកដ្ឋានហិរញ្ញវត្ថុ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh